HARBOR REGIONAL CENTER

# ក្រឹត្យ ABLE និង CalABLE៖ *ការផ្តល់សន្តិសុខហិរញ្ញវត្ថុធំធេង សំរាប់មនុស្សដែលពិការ*

**ការសំរេចបទពិសោធន៍ជីវិតល្អប្រសើរ កាលីហ្វ័រនីញ៉ា (California Achieving a Better Life Experience, CalABLE)** គឺជាកម្មវិធីមួយ ដែលអនុញ្ញាតឲ្យមនុស្សដែលពិការ ដើម្បីស្ថាបនា **គណនី ABLE** អត់ខិនពន្ធមួយ ដែលអនុញ្ញាតឲ្យគេសន្សំប្រាក់ដល់ទៅ $100,000 ដោយមិនបាត់បង់អត្ថប្រយោជន៍សាធារណៈ ដូចជា SSI, SSDI និង Medi-Cal។ ប្រាក់រកបាននៅក្នុងគណនីទាំងនេះ គឺមិនបង់ពន្ធប្រាក់ចំណូលសហព័ន្ធ ឬពន្ធប្រាក់ចំណូលរដ្ឋកាលីហ្វ័រនីញ៉ាទេ ដរាបណាប្រាក់រកបាន ត្រូវបានចាយវាយលើ ចំណាយមានសិទ្ធិទទួលភាពពិការ (Qualified Disability Expenses)។ **ក្រឹត្យ ABLE** ពីមុន បុគ្គលម្នាក់ដែលកំពុងទទួលអត្ថប្រយោជន៍ ពីកម្មវិធីសាធារណៈ មិនអាចសន្សំប្រាក់បានលើសពី $2,000 ដោយគ្មានបានព្យួរអត្ថប្រយោជន៍របស់គេទេ។

## <u>ប្រវត្តិ</u>

- ក្នុងឆ្នាំ 2014 លោកប្រធានាធិបតី Obama បានចុះហត្ថលេខាច្បាប់ Stephen Beck, Jr. ហៅថា **ក្រឹត្យការសំរេចបទពិសោធន៍ជីវិតល្អប្រសើរ (Achieving a Better Life Experience Act**, IRC វគ្គ 529A)។
- ក្នុងឆ្នាំ 2015 អង្គនីតិបញ្ញត្តិរដ្ឋកាលីហ្វ័រនីញ៉ា បានបង្កើតកម្មវិធីមួយហៅថា **គណៈការសំរេចបទពិសោធន៍ជីវិតល្អប្រសើរ កាលីហ្វ័រនីញ៉ា (California Achieving a Better Life Experience Board, CalABLE)** ដើម្បីប្រតិបត្តិកម្មវិធី ABLE ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

## <u>ការតម្រូវសិទ្ធិទទួល</u>

ដើម្បីឲ្យមានសិទ្ធិស្ថាបនាគណនី **ABLE ឬ <u>CalABLE</u>** មួយបាន បុគ្គលម្នាក់ត្រូវតែមានភាពពិការ ដែលបានចាប់ផ្តើមមុនអាយុ 26 ឆ្នាំ ថ្វីបើ <u>ក្រឹត្យ ABLE កែសំរួលអាយុ</u> ទើបបានចុះហត្ថលេខាថ្មីៗទៅជាច្បាប់ក្តី ការផ្លាស់ប្តូរនេះ ទៅអាយុ 46 ឆ្នាំ មានប្រសិទ្ធិភាពនៅថ្ងៃទី 1 ខែមករា 2026។ លើសពីនេះទៀត បុគ្គលម្នាក់ត្រូវតែយ៉ាងហោច ជួបលក្ខណៈមួយខាងក្រោម៖

- ដើម្បីមានសិទ្ធិទទួល ប្រាក់ចំណូលសឺគ្យូរិទីបន្ថែម (Supplemental Security Income, SSI) ឬ សូស្យ៉ាល់សឺគ្យូរិទីធានារ៉ាប់រងភាពពិការ (Social Security Disability Insurance, SSDI) ពីព្រោះតែភាពពិការរបស់គេ; ឬ
- អាចផ្តល់ "ការបញ្ជាក់ខ្លួនឯង" នូវភាពពិការ និងរោគវិនិច្ឆ័យរបស់គេ។ នេះមានសេចក្តីថា បុគ្គលមានរោគវិនិច្ឆ័យលាយល័ក្ខអក្សរ បានចុះហត្ថលេខា មកពីគ្រូពេទ្យមានអាជ្ញាប័ណ្ណ ដែលមានផ្តល់ជូនតាមសំណូមពរ។

## <u>ការបរិច្ចាគទៅគណនី</u>

ការបរិច្ចាគទៅគណនី ABLE នៅបច្ចុប្បន្ននេះ មានកម្រិតដល់ <u>$17,000</u> មួយឆ្នាំ និងអាចបានបរិច្ចាគដោយគ្រួសារ មិត្រភ័ក្តិ ឬអ្នកទទួលអត្ថប្រយោជន៍ ខ្លួនគេផ្ទាល់។ គណនីរកប្រាក់បាន ត្រូវបានអនុញ្ញាតឲ្យកើនប្រាក់មិនបង់ពន្ធ និងការដកប្រាក់ចេញ ប្រសិនគេបានដាក់ពាក្យសុំ ចំណាយមានសិទ្ធិទទួលភាពពិការ ក៏មិនបង់ពន្ធដែរ។

ការកែឲ្យទាន់សម័យថ្មីៗ ដែលមានឥទ្ធិពលដល់ ការបរិច្ចាគទៅគណនី រួមមានដូចតទៅ៖

<u>ក្រឹត្យ ABLE ដើម្បីធ្វើការ៖</u> ម្ចាស់គណនី ABLE ដែលធ្វើការ អាចនឹងមានសិទ្ធិធ្វើបរិច្ចាគលើសពី $17,000 នៃកម្រិតការបរិច្ចាគប្រចាំឆ្នាំ ជាបន្ថែមដល់ទៅ $13,590 អាស្រ័យលើប្រាក់ចំណូលរួមរបស់គេ។ ការបរិច្ចាគបន្ថែមទាំងនេះ ដែលបានអនុញ្ញាត នឹងមានកម្រិតចំពោះចំនួន ដែលបានធ្វើដោយម្ចាស់គណនី។

<u>ក្រឹត្យការរៀបចំហិរញ្ញវត្ថុ ABLE៖</u> ថវិកានៅក្នុង គណនីសន្សំប្រាក់សំរាប់មហាវិទ្យាល័យ 529 អាចនឹងបង្វែរគណនី ABLE ដោយគ្មានពន្ធអ្វី ឬពិន័យទេ ប្រសិនអ្នកទទួលអត្ថប្រយោជន៍ ជាមនុស្សដដែលនៅលើគណនីទាំងពីរ។ ថវិកាដែលបានផ្ទេរ គឺនៅតែប្រព្រឹត្តតាម ABLE កម្រិតការបរិច្ចាគប្រចាំឆ្នាំ។

ខែកុម្ភៈ 2023

HARBOR REGIONAL CENTER

<u>ឥណទានរបស់អ្នកសន្សំប្រាក់៖</u> ម្ចាស់គណនី ABLE ដែលបរិច្ចាគប្រាក់ចំណូលរបស់ខ្លួនគេ ចូលទៅគណនី ABLE របស់គេ អាចនឹងមានសិទ្ធិទទួលផលប្រយោជន៍ ឥណទានពន្ធនៃការបរិច្ចាគសន្សំប្រាក់និវត្តន៍ (Retirement Savings Contributions Tax Credit) ឬ "ឥណទានរបស់អ្នកសន្សំប្រាក់" (Saver's Credit)។ ព័ត៌មានថែមទៀតអំពី ឥណទានរបស់អ្នកសន្សំប្រាក់ រួមទាំងការតម្រូវសិទ្ធិទទួល គឺមាននៅលើ [គេហទំព័រ IRS។](#)

**<u>ចំណាយមានសិទ្ធិទទួលភាពពិការ</u>**

ការចាយវាយត្រូវបានចាត់ទុកជា "មានសិទ្ធិទទួល" នៅពេលវាទាក់ទងនឹងភាពពិការរបស់មនុស្ស និងជួយគេរក្សា ឬលើកកំពស់សុខភាព ឬភាពម្ចាស់ការ ឬគុណភាពជីវិតរបស់គេ។ ចំណាយមានសិទ្ធិទទួលភាពពិការ គឺមិនកម្រិតចំពោះចំណាយថ្លៃពេទ្យទេ។ វាអាចនឹងបញ្ចូលការចំណាយលើការរស់នៅជាគោល ដូចជា ចំណាយសំរាប់ការអប់រំ, ទីលំនៅ, យានជំនិះ, ការគាំទ្រការងារ, សុខភាព, ការការពារ និងជាសុកភាព, ជំនួយបច្ចេកទេស, សេវាហិរញ្ញវត្ថុ, ការកែផ្ទះ និងសេវាបុណសព។

**<u>ទ្រង់ទ្រាយគណនី CalABLE</u>**

គណៈ CalABLE បានសំរេចថាទ្រង់ទ្រាយគណនី និងអត្ថប្រយោជន៍ នៅរដ្ឋកាលីហ្វ័រនីញ៉ា រួមមាន៖

- សមត្ថភាពដើម្បីបរិច្ចាគជាស្វ័យប្រវត្តិ តាមរយៈការកាត់ចេញជាប្រក្រតី ចេញពីគណនីធនាគារ;
- បញ្ចូលប្រាក់តាមអនឡាញ ឬដោយសែក រួមទាំងការបរិច្ចាគមកពីគ្រួសារ និង/ឬ មិត្រភ័ក្តិ;
- ប្រើឥណទានប័ណ្ណបង់ប្រាក់មុន; និង
- ថ្លៃឈ្នួលដូចគេឯង និងជំរើសវិនិយោគចំរុះ។

ទៅមើល [CalABLE.ca.gov](#) សំរាប់ព័ត៌មានអំពីរបៀប **បើកគណនីមួយ និងជំរើសវិនិយោគ/ថ្លៃឈ្នួល។**

នីតិកម្មដែលបានចុះហត្ថលេខាដោយអភិបាលរដ្ឋ គូសបញ្ជាក់កត្តាសំខាន់ៗខាងក្រោម៖

- គណនី CalABLE របស់អ្នកមូលដ្ឋានរដ្ឋកាលីហ្វ័រនីញ៉ា នឹងមិនមែនជាកម្មវត្ថុការទារយកដោយ Medi-Cal (SB 218) ទេ។
- CalABLE នឹងជាកម្មវិធីជាតិ ដែលអនុញ្ញាតឲ្យការចូលរួម នៃអ្នកមូលដ្ឋាន មិននៅរដ្ឋកាលីហ្វ័រនីញ៉ា (AB 384)។
- គណនី CalABLE គឺលើកលែងចេញពីការជំនុំជំរះបង្ខំយកប្រាក់ (AB 688)។

**ការសំរេចបទពិសោធន៍ ជីវិតល្អប្រសើរ កាលីហ្វ័រនីញ៉ា (CalABLE)**



CalABLE បានធ្វើជាដៃគូជាមួយ វិជ្ជាស្ថានភាពពិការជាតិ (National Disability Institute) ដើម្បីបង្កើតនូវ **AchievABLE Corner** ជាធនធានសំរាប់បុគ្គល/គ្រួសារ ទាំងពួង; ទៅមើល **[nationaldisabilityinstitute.org/achievable-corner](#)**។

**<u>កម្មវិធី ABLE នៅពាសពេញសហរដ្ឋ</u>**

កម្មវិធី ABLE ខ្លះ អនុញ្ញាតឲ្យអ្នកមូលដ្ឋាន នៅក្រៅរដ្ឋ ដើម្បីបើកគណនី ABLE មួយ។ ដើម្បីស្វែងយល់អំពីកម្មវិធី ABLE របស់រដ្ឋដទៃ អ្នកអាចប្រើប្រដាប់នេះ ដើម្បីប្រៀបធៀប៖ **[ablenrc.org/compare-states](#)**។

ខែកុម្ភៈ 2023